# សុន្ទរកថាសំខាន់

### ថ្លែងដោយ

### សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

### នៃព្រះរាជាណាចក្រកម្ពុជា

## ក្នុងពិធីប្រគល់ប័ណ្ណអាហារូបករណ៍

# សម្តេចតេជោ ហ៊ុន សែន ចក្ខុវិស័យ ១០០

### វិទ្យាស្ថានជាតិអប់រំ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨

**ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ**
**លោកស្រី អស់លោក និង ក្មួយៗជានិស្សិតទាំងអស់ ជាទីស្នេហា !**

ព្រឹកនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ និង កិត្តិយសដ៏ខ្ពង់ខ្ពស់ដោយបានចូលរួម ក្នុងពិធីប្រគល់ប័ណ្ណអាហារូបករណ៍ “ **សម្តេចតេជោ ហ៊ុន សែន ចក្ខុវិស័យ ១០០** ” ដែលរៀបចំឡើងដោយ សាកលវិទ្យាល័យកម្ពុជា ។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះការខិតខំប្រឹងប្រែងរបស់សាកលវិទ្យាល័យកម្ពុជា ក្នុងការស្វែងរកអាហារូបករណ៍ពេញថ្លៃ រាប់រយកន្លែងសម្រាប់ជួយនិស្សិតយើង ដែលមានជីវភាពក្រីក្រ តែរៀនពូកែ អោយបានបន្តការសិក្សាទៅថ្នាក់ឧត្តម ។ វិភាគទាននេះ គឺជាការរួមចំណែកលើកស្ទួយការអភិវឌ្ឍធនធានមនុស្ស និងការកាត់បន្ថយភាពក្រីក្រ ដែលប្រទេសជាតិ និង ប្រជាជនយើងកំពុងត្រូវការ ។

សូមអរគុណចំពោះបណ្ឌិត Rikhi Thakral ប្រធានក្រុមហ៊ុន Thakral Holding Group នៃសាធារណរដ្ឋសឹង្ហបូរី និង ក្រុមគ្រួសារ ព្រមទាំងសហការី ដែលបានជួយឧត្ថម្ភអាហារូបករណ៍ចក្ខុវិស័យ ១០០ និង ដែលបានប្រសិទ្ធិនាមអាហារូបករណ៍នេះ តាមឈ្មោះរបស់ខ្ញុំ ។

ម្យ៉ាងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះគណៈអធិបតី ភ្ញៀវជាតិ និង អន្តរជាតិ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ អញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់ប័ណ្ណអាហារូបករណ៍ដ៏មានសារៈសំខាន់នេះ ។

ព្រមជាមួយគ្នានេះ ខ្ញុំសូមសរសើរដល់ក្មួយៗទាំងអស់ ជានិស្សិតឆ្នើមទាំង ១០០ នាក់ ដែលបានទទួលជោគជ័យ ក្នុងការប្រកួតប្រជែងដណ្តើមយក **អាហារូបករណ៍ ចក្ខុវិស័យ ១០០** ដ៏ស្រួចស្រាល់នេះ ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**

តទៅនេះ ដើម្បីអោយការសិក្សារបស់ក្មួយៗជោគជ័យ ខ្ញុំសូមជូនមតិខ្លះ ដូចខាងក្រោម :

**I- *សំណូមពររបស់ខ្ញុំចំពោះមាតាបិតា :***

១- ជាការពិតណាស់ បុត្រធីតារបស់យើងពុំអាចរីកលូតលាស់បានទេ ប្រសិនបើមាតាបិតានៅតែដឹកដៃគេរហូតនោះ ។ ការផ្តល់ឱកាស និង សេរីភាពអោយបុត្រធីតារៀនទទួលខុសត្រូវដោយខ្លួនឯង រៀនគិតគូរ និង រៀនធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯងបណ្តើរៗនៅក្នុងវ័យសិក្សាថ្នាក់ឧត្តមរបស់គេ គឺជាការសំខាន់ណាស់ ។ ធ្វើដូច្នេះ គឺដើម្បីអោយគេរៀនរស់ និង រៀនដើរយ៉ាងរឹងមាំឆ្ពោះទៅអនាគត ។

២- សាកលវិទ្យាល័យ គឺជាទីកន្លែងមួយដែលជួយធ្វើឱ្យបុត្រធីតារបស់យើង មានការរីកចំរើន និង ក្លាយជាមនុស្សពេញវ័យ ។ សាកលវិទ្យាល័យ គឺជាទីកន្លែងដែលនិស្សិតត្រូវធ្វើការដកពិសោធន៍ រៀនដឹងខុសដឹងត្រូវតាមរយៈការ សិក្សាដោយផ្ទាល់របស់គេ ។ ការសិក្សានៅសាកលវិទ្យាល័យ គឺជាឱកាសដែលមាតាបិតាត្រូវលែងដៃអោយ កូនដើរបន្តិចម្តងៗ ឆ្ពោះទៅរកជីវិតដែលគេស្រឡាញ់ពេញចិត្ត ។ គឺតាមរយៈការជ្រើសរើស និង ការធ្វើអោយជោគជ័យនូវជីវិតមួយ ដែលប្រកបដោយសេចក្តីស្រឡាញ់ពេញចិត្តនេះហើយ ដែលធ្វើឱ្យកូនយើង ក្លាយជាមនុស្សពិត ជាមនុស្សដែលមានទេពកោសល្យ និង ជា “មហាបុរស” ទៅអនាគត ។

**II- *ចំពោះក្មួយៗជានិស្សិតឆ្នើមទាំង ១០០ នាក់ ដែលបានទទួលប័ណ្ណអាហារូបករណ៍ចក្ខុវិស័យ ១០០ ក្នុងពេលនេះ សូមចាំថា :***

**១- <u>*គោលដៅច្បាស់លាស់ និង ភាពមោះមុត ជួយអោយការសិក្សាបានជោគជ័យ:*</u>**

ការសិក្សាត្រូវមានគោលដៅច្បាស់លាស់ ។ ដូច្នេះ ក្មួយៗដែលនឹងទទួលបានអាហារូប ករណ៍ថ្មី ត្រូវតែកំណត់គោលដៅនៃការសិក្សារបស់ខ្លួន ឬ មុខវិជ្ជាឯកទេសរបស់ខ្លួនឱ្យបានច្បាស់លាស់ ។ បន្ទាប់មក

ត្រូវរៀបចំកម្មវិធីរៀនសូត្រឱ្យបានត្រឹមត្រូវតាមគោលដៅនោះ ។ គោលដៅនៃការសិក្សា ត្រូវកំណត់ដោយខ្លួនឯង ពុំមែនកំណត់ដោយអ្នកដទៃឡើយ ថ្វីបើមតិរបស់អ្នកដទៃចាំបាច់ត្រូវស្វាគមន៏ ។

## ២. ពេលវេលា គឺជាមាសពេជ្រដ៏មានតម្លៃ:

ការគ្រប់គ្រងពេលវេលា ក្នុងការសិក្សាឱ្យបានល្អ គឺជាការចាំបាច់ណាស់ ។ ពេលមួយនាទីស្មើពេជ្រមួយគ្រាប់។ សូមក្មួយៗក្តាប់យកឱកាសសិក្សា ដើម្បីយកប្រយោជន៍ពីចំណេះដឹងអោយបានល្អ ។ ចូរកុំបណ្តោយឱ្យពេលវេលាកន្លងទៅដោយពុំបានសិក្សា ក្រេបជញ្ជក់យកចំណេះដឹង សម្រាប់អនាគត របស់ខ្លួន។

## ៣. ការសិក្សានៅសាកលវិទ្យាល័យ គឺជាឱកាសដ៏កម្រមួយ:

បច្ចុប្បន្ននេះ ចំនួនសិស្សដែលបានបញ្ចប់ការសិក្សានៅថ្នាក់មធ្យមសិក្សា កាន់តែកើនឡើង ក៏ប៉ុន្តែចំនួនអាហារូបករណ៍ ដែលគ្រឹះស្ថានសិក្សារដ្ឋ និង ឯកជនផ្តល់ជូននៅមានកំរិត ។ ទន្ទឹមនេះ ភាពក្រីក្រគឺជាឧបសគ្គនៃការសិក្សា ។ ដូច្នេះ ការទទួលបានអាហារូបករណ៍នេះ គឺជាឱកាសដ៏កម្រ ដែលក្មួយៗមិនត្រូវធ្វើឱ្យបាត់បង់ទៅវិញទេ ។ ការខិតខំរៀនសូត្រ ការគ្រប់គ្រងពេលវេលា ការគោរពបទបញ្ជា និងក្រមសីលធមិសិក្សា ក៏ដូចជាការគោរពឱវាទរបស់គ្រូ គឺជាកត្តាចាំបាច់ដែលជួយធ្វើអោយក្មួយៗរក្សាបាននូវឱកាសសិក្សា ក្នុងថ្នាក់ឧត្តមដ៏កម្រនេះ ។

## ៤. បើមានភាពបរាជ័យក្នុងការសិក្សា ចូរកុំបោះបង់ចោលការរៀនសូត្រ:

សូមក្មួយៗចាំថា ទាំងជោគជ័យ ទាំងបរាជ័យ ក្នុងការសិក្សាពុំមែនមានតែរហូតទេ ។ ពេលខ្លះយើងសិក្សាបានជោគជ័យ ។ ពេលខ្លះ យើងជួបនឹងភាពបរាជ័យក្នុងការសិក្សា ។ ដូច្នេះ ពេលក្មួយៗសិក្សាបានជោគជ័យ គួរតែខិតខំបន្តការសិក្សាឱ្យបានខ្លាំងក្លាថែមទៀត បើពុំដូច្នេះទេ ក្មួយៗអាចនឹងបរាជ័យវិញជាមិនខាន ។ ក៏ប៉ុន្តែ បើបរាជ័យហើយ ចូរកុំបោះបង់ចោលការរៀនសូត្រ ។ ចូរខិតខំស៊ូ-ព្យាយាមរៀនសូត្ររហូតដល់បានទទួលជោគជ័យឡើងវិញ ។ បើទទួលបានជោគជ័យហើយ ក្មួយៗគួរតែខិតខំព្យាយាមធ្វើអោយជោគជ័យនោះ កាន់តែ **“លេចធ្លោរ”** ឡើង ។ ធ្វើដូច្នេះបាន នោះក្មួយៗនឹងទទួលបានជោគជ័យក្នុងការសិក្សា ជានិច្ចនិរន្តន៍ ។

## ៥. សេចក្តីភ័យខ្លាច និង ការខ្មាសអៀន គឺជាឧបសគ្គនៃការសិក្សា:

ជាធម្មតា ឧបសគ្គធំបំផុតសម្រាប់ការសិក្សា គឺសេចក្តីខ្មាសអៀន ឬ ការភ័យខ្លាច ។ គុណវិបត្តិទាំងនេះ មានមកតាំងតែពីកំណើតរបស់មនុស្ស ។ ការមានអារម្មណ៍ដូច្នេះ ពុំត្រឹមត្រូវទេ ។ ការសិក្សា ឬការរៀនសូត្រ ក្នុងការធ្វើអ្វីមួយពីដំបូងតែងមានកំហុសជាធម្មតា តែដល់ធ្វើយូរៗទៅ កំហុសនោះ នឹងជំនួស

ដោយចំណេះដឹងថ្មី នោះ គឺជាចំណេះដឹងដែលបានមកពីភាពខុសឆ្គង ។ ដូច្នេះ ចូរក្មួយៗកុំខ្លាចខុស តែបើខុស ហើយត្រូវខិតខំរៀនធ្វើអោយត្រូវឡើងវិញ ។ ចូរកុំបណ្តែតបណ្តោយអោយកំហុសនោះ កើតមានឡើង ដដែលៗ ដោយគ្មានការកែប្រែ ។

ម្យ៉ាងទៀត ពេលក្មួយៗមានកំហុស ចូរកុំបន្ទោសអ្នកដទៃ ពោលគឺត្រូវបន្ទោសខ្លួនឯង ។ ក៏ប៉ុន្តែ ក្មួយៗក៏មិនគួរបន្ទោសខ្លួនឯងថា **"អន់ជ្រុល"** រហូតដល់ **"តូចចិត្តនឹងវាសនា"** **"អស់សង្ឃឹម"** ហើយ **"ដេកលែងក្រោក"** នោះឡើយ ។ ធ្វើដូច្នេះ ពុំត្រឹមត្រូវទេ ។ ពេលដួលហើយ ក្មួយៗត្រូវតែក្រោកឡើងវិញ ហើយត្រូវ រៀនដើរទៀត គឺដើររហូតដល់លែងដួល និង ចេះតែដើរយ៉ាងរឹងមាំ ឆ្ពោះទៅអនាគតដ៏រុងរឿង របស់ខ្លួន ។

## ៦. ជំនឿទុកចិត្ត គឺជាជីវជាតិនៃការសិក្សា

នៅលើលោកនេះ ជំនឿទុកចិត្តលើអាត្មាខ្លួន គឺជាថាមពល និង ជាជីវជាតិនៃការសិក្សា ។ ធ្វើអ្វីក៏ដោយ បើយើងមានជំនឿថា យើងអាចធ្វើបាន យើងពិតជាអាចធ្វើបាន ។ ផ្ទុយទៅវិញ បើយើងពុំជឿថា យើងអាចធ្វើបានទេ យើងពុំអាចធ្វើបានឡើយ ។ ជំនឿលើអាត្មាខ្លួន គឺជាកត្តាកំណត់ជោគជ័យមួយ ក្នុងការធ្វើការងារអ្វីៗទាំងអស់ ។ ដូច្នេះ ចូរក្មួយខិតខំបណ្តុះជំនឿទុកចិត្តលើខ្លួនយើង នោះទើបការសិក្សារបស់ក្មួយបាន សម្រេចជោគជ័យ ។

## ៧. ការងារដែលថ្លៃថ្នូរ គឺការងារដែលយើងស្រឡាញ់ពេញចិត្ត

ក្នុងជីវិតសិក្សា ក្មួយៗគួរចាប់ផ្តើមគិតពី **"អាជីព"** របស់ក្មួយ ចាប់តាំងពីពេលនេះទៅ ។ ក្មួយៗពុំគួរទុករហូតដល់សិក្សាចប់ទើបគិតពីអាជីពរបស់ខ្លួន នោះពុំត្រឹមត្រូវទេ ។ ធ្វើដូច្នេះ គឺដើម្បីអោយយើងមានពេលគិតជាបណ្តើរៗ និង ដើម្បីឱ្យយើង ធ្វើសេចក្តីសម្រេចចិត្តត្រឹមត្រូវ ។ ក៏ប៉ុន្តែ ទោះជាដូចម្តេចក្តី ក្មួយៗពុំគួរជ្រើសរើសយកតែការងារណាដែលបានប្រាក់ច្រើនទេ ព្រោះថា ប្រាក់ជួនកាលធ្វើអោយយើងធុញទ្រាន់នឹងការងារក៏មានដែរ ។ ដូច្នេះ ក្មួយៗគួរតែជ្រើសរើសយកការងារណាដែលយើងស្រឡាញ់ពេញចិត្ត នោះទើបមានការរីកចំរើន ។

## ៨. អនាគត គឺជាផលិតផលនៃបច្ចុប្បន្ន

ជាការពិតណាស់ ក្នុងជីវិតនេះ គ្មាននរណាឡើយដែលអាចត្រឡប់ទៅអតីតកាល ហើយអាចចាប់ផ្តើមធ្វើអ្វីមួយអោយល្អឡើងវិញបាន។ ពេលវេលាដែលកន្លងទៅ ពុំអាចវិលត្រឡប់វិញបានទេ ។ រាល់ការ

ស្រមើស្រមៃតែពីអតីតកាល គ្មានបាននាំមកនូវអ្វីក្រៅពីសេចក្តីសោកស្តាយ ការខកចិត្ត និង ការអស់សង្ឃឹម តែប៉ុណ្ណោះ ។ ជីវិតនេះ ពុំមែនជាការខកចិត្តឡើយ គឺជាការតស៊ូ និង ជាភាពសុទិដ្ឋិនិយម ។ សូមក្មួយៗកុំរស់ក្នុងអតីតកាល ! សូមរស់ក្នុងបច្ចុប្បន្នកាល នោះទើបអនាគតរបស់ក្មួយៗបានល្អប្រសើរ !

សរុបសេចក្តីមក ដើម្បីឱ្យជីវិតនៃការសិក្សារបស់ក្មួយៗបានប្រកបដោយជោគជ័យ ក្មួយៗគួរតែតាំងខ្លួន ជាមនុស្សដ៏ឧត្តម ស្លូតបូត សុភាពរាបសារ ឧស្សាព្យាយាម ចំរើនជឿនលឿន — គួរឈរឱ្យបានរឹងមាំក្នុងតួនាទីជាម្ចាស់នៃជីវិតរបស់ខ្លួន — គួរជួយខ្លួនឯងអោយល្អបំផុត មុនអោយអ្នកដទៃជួយខ្លួនយើង — តែក៏ពុំគួរក្លាយខ្លួនជាមនុស្សអន់ថយ ទុទិដ្ឋិនិយមឡើយ ។

**គណៈអធិបតី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និង ក្មួយៗជានិស្សិត !**

ក្នុងនាមជាចាស់ទុំមួយរូប ដែលធ្លាប់បានឆ្លងកាត់ការសិក្សាទាំងក្នុងថ្នាក់ និង ក្រៅថ្នាក់ ពោលគឺ “ **សាលាជីវិត** ” សឹងពេញមួយជីវិតរបស់ខ្ញុំ ខ្ញុំសូមជូនមតិណែនាំក្មួយៗតែប៉ុណ្ណោះ ។ ខ្ញុំសង្ឃឹមថា មតិទាំងនេះអាចនឹងបានជាជំនួយស្មារតីខ្លះដល់ក្មួយៗ ដើម្បីចាប់យកចំណេះដឹងថ្នាក់ឧត្តមដ៏មានតម្លៃសម្រាប់អនាគតក្មួយ និងប្រទេសជាតិយើង។

ជាថ្មីម្តងទៀត នៅទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ **គណៈអធិបតី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាភ្ញៀវជាតិ និង អន្តរជាតិ** ដែលបានអញ្ជើញចូលរួមក្នុង **ពិធីប្រគល់ប័ណ្ណអាហារូបករណ៍ ចក្ខុវិស័យ ១០០** ជាពិសេស សូមថ្លែងអំណរគុណចំពោះ បណ្ឌិត Rikhi Thakral និង សហការី ដែលបាន ឧបត្ថម្ភទាំងស្រុងដល់អាហារូបករណ៍នេះ ។

សូមជូនពរគណៈអធិបតី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាភ្ញៀវជាតិ និង អន្តរជាតិ ព្រមទាំងក្មួយៗ សូមអោយបានប្រកបដោយ **ជោគជ័យ សិរីមង្គល និង វិបុលសុខ** កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ !**